ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Dec-2018, 13:15
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

Isaac Endeley
ប្រធានអង្គភាពគាំពារការការពារក្តី

ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

ជូនចំពោះ៖ លោក Victor Koppe
ក្រុងអាំស្ទ័រដាំ ប្រទេសហូឡង់

**តាមអ៊ីមែល**

**កម្មវត្ថុ៖ ការបញ្ចប់កិច្ចសន្យាផ្តល់សេវាផ្នែកច្បាប់របស់លោកធ្វើជាតំណាងលោក នួន ជា នៅ អ.វ.ត.ក**

ជូនចំពោះលោក Victor Koppe៖

១. ខ្ញុំសរសេរអ៊ីមែលនេះដោយភ្ជាប់មកជាមួយនូវលិខិតមួយច្បាប់ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("គណៈមេធាវី") ដែលបានរម្លឹកខ្ញុំអំពីសេចក្តីសម្រេចរបស់គណៈមេធាវី ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ដែលបានសម្រេចដកឈ្មោះរបស់លោកចេញពីបញ្ជីមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅក្នុងតុលាការកម្ពុជា។ ខ្ញុំទើបតែទទួលបានអត្ថបទបកប្រែជាភាសាអង់គ្លេសនៃលិខិតនេះ ដែលសូមភ្ជាប់មកជាមួយផងដែរ។

២. ទាក់ទិននឹងពាក្យពេចន៍យ៉ាងច្បាស់របស់គណៈមេធាវីដែលថា គណៈមេធាវីជាស្ថាប័នតែមួយគត់ដែលមានអំណាចអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈច្បាប់នៅកម្ពុជា ខ្ញុំមានការសោកស្តាយសូមជូនដំណឹងដល់លោកថា អង្គភាពគាំពារការការពារក្តី ("អ.គ.ក") មិនអាចបន្តកិច្ចសន្យាការងារជូនលោកក្នុងនាមជាសហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា បានទៀតទេ។ ហេតុនេះ ខ្ញុំសូមជូនដំណឹងដល់លោកថា ការអនុញ្ញាតឱ្យលោកធ្វើជាតំណាងលោក នួន ជា នៅ អ.វ.ត.ក ត្រូវបានបញ្ចប់**ចាប់ពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨ តទៅ**។ ក៏ប៉ុន្តែ អនុលោមតាមការអនុវត្តន៍ដែលត្រូវបានបង្កើតឡើងនៅ អ.គ.ក លោកនឹងត្រូវបានទទួលការអនុញ្ញាតឱ្យបន្តការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីបំពេញទៅតាមទម្រង់បែបបទរដ្ឋបាលមួយចំនួន ដូច

ជា នីតិវិធីនៃការបំពេញបែបបទចេញ និងការប្រគល់សម្ភារៈពាក់ព័ន្ធនឹងសំណុំរឿងដល់សហមេធាវីជាតិការពារក្តីលោក នួន ជា។ ហេតុនេះ ការអនុញ្ញាតផ្នែករដ្ឋបាលដែលបានផ្តល់ជូនលោកសម្រាប់ចិរវេលាក្រោយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវទុកជាមោឃៈ។

៣. ខ្ញុំសូមឆ្លៀតឱកាសនេះធ្វើការថ្លែងអំណរគុណដល់លោក ដែលបានបំពេញការងារជាច្រើនឆ្នាំជាមួយ អ.គ.ក ហើយខ្ញុំសូមជូនពរលោកឲ្យមានសំណាងល្អក្នុងការសម្រេចគោលដៅនានាទៅអនាគត។

សូមលោកទទួលនូវការរាប់អានពីខ្ញុំ

Isaac Endeley

ប្រធានអង្គភាពគាំពារការការពារក្តី

ចម្លងជូន៖

លោក សុន អរុណ សហមេធាវីជាតិការពារក្តីលោក នួន ជា

លោក លឹម សុធា មន្ត្រីទទួលបន្ទុក ផ្នែកគ្រប់គ្រងធនធានមនុស្ស

លោក Sojan VATTAPALLAY ប្រធានផ្នែកថវិកា និងហិរញ្ញវត្ថុ

មន្ត្រីច្បាប់ជាន់ខ្ពស់ និងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង

លោក-លោកស្រីចៅក្រមអង្គជំនុំជម្រះសាលាដំបូង